ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តសៀមរាប**

សាលក្រមព្រហ្មទណ្ឌលេខ៖ ៣៦ "ង"៤៣៥
ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២
សំណុំរឿងព្រហ្មទណ្ឌលេខ : ៣៧២
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ : ២០៥
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ : ៣៤០
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២

- បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប ។
- កាលបរិច្ឆេទបើកសវនាការជំនុំជម្រះ៖ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។
- កាលបរិច្ឆេទប្រកាសសាលក្រម៖ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២។

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៧២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] ព្រំ [redacted] ខេត្តសៀមរាប មុខរបរលក់ដូរ កម្រិតវប្បធម៌ថ្នាក់ទី៤ ប្រពន្ធឈ្មោះ [redacted] កក្កដា មានកូន០១នាក់(លែងលះ) ឪពុកឈ្មោះ [redacted] ឈឿន "រស់" ម្តាយឈ្មោះ [redacted] ចាន់ថា "រស់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

☑ ក្នុងឃុំ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖ ២១៥ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ។

-ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ៖ " **ប៉ុនប៉ងរំលោភសេពសន្ថវៈ** " ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

ជនរងគ្រោះឈ្មោះ [redacted] មករា ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ។

បានឃើញ ដីកាដំណោះស្រាយលេខ៖ ១៩៥២ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

បានឃើញ កំណត់ហេតុជំនុំជម្រះ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ។

## អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ស្ថិតនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ជនសង្ស័យ ឈ្មោះ[redacted] ចាន់ធឿន ភេទប្រុស អាយុ៤១ឆ្នាំ(ជាអតីតបងថ្លៃ)បានស្លៀកកន្សែងអត់អាវ សួរនាំជនរងគ្រោះឈ្មោះ [redacted]មករា ភេទស្រី អាយុ៣៨ឆ្នាំ រកប្រេងឆា។ ដោយឃើញឱកាសស្ងាត់ ជនសង្ស័យបានស្ទុះចូលមកខ្ទប់មាត់ និងផ្តួលជនរងគ្រោះទៅលើពូក ប៉ុន្តែត្រូវជនរងគ្រោះរើបម្រាសរួច ដោយបានចាប់បោចសក់ ច្រានមុខចេញនិងប្រើជើងធាក់ទ្រូង បណ្តាលឲ្យជនសង្ស័យដួលអុកគូថ ហើយបានសុំទោសនិងដើរចេញទៅបាត់ ។ ក្រោយមកជនរងគ្រោះបានទៅដាក់ពាក្យបណ្តឹងមកសមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]ចាន់ធឿន បានឆ្លើយថា ៖កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៧ និង៣០នាទីព្រឹក ខ្លួនក្រោកពីដេកស្លៀកក្រម៉ាពុំមានពាក់អាវនិងស្លៀកខោលីអូទេ បានដើរចូលទៅផ្ទះប្រពន្ធខ្លួនពេលបើទ្វារទៅឃើញឈ្មោះ លន់ មករា កំពុងអង្គុយជាមួយកូនប្រុស អាយុប្រហែល៤ឆ្នាំ នៅមុខបន្ទប់ទ្វារដេកពេលនោះខ្លួនសុំឈ្មោះ[redacted]មករា ថាមានខ្លាញ់ទេ ពេលនោះឈ្មោះ[redacted]មករា ឆ្លើយថាខ្លាញ់មាននៅខាងក្រោយដើរទៅយកទៅ ។ ពេលនោះខ្លួនដើរទៅមិនទាន់បានយកខ្លាញ់ទេគឺចូលទៅប្រវាយប្រតប់គ្នាជាមួយឈ្មោះ [redacted] មករា ខ្លួនបានខ្ទប់មាត់ និងបំរុងធ្វើសកម្មភាពចាប់រំលោភ តែត្រូវឈ្មោះ លន់ មករា ធាក់មួយជើងចំដើមទ្រូងផ្ងាកក្រោយ ហើយឈ្មោះ [redacted] មករា ស្រែកខ្លាំងៗថា អាពៅកុំធ្វើអញ្ចឹង ពេលនោះកូនរបស់ឈ្មោះ[redacted]មករា ក៏ស្រែកយំខ្លាំងៗខ្លួនបានដើរចេញមកក្រៅផ្ទះវិញ ក្រោយមកខ្លួនក៏បានលុតជង្គង់សុំទោសឈ្មោះ [redacted] មករា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]មករា បានឆ្លើយថា កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៦ និង៣០នាទី អ្នកផ្ទះខ្លួនឈ្មោះ [redacted] កក្កដា បានចេញទៅលក់នំ ចំណែកកូនស្រីឈ្មោះ[redacted] សុផានីតា បានទៅរៀន កូនប្រុសឈ្មោះ [redacted]សុវណ្ណារ៉ា អាយុ៣ឆ្នាំ នៅផ្ទះជាមួយខ្លួន ។ លុះដល់ម៉ោង៧និង៣០នាទីព្រឹក ឈ្មោះ[redacted] ចាន់ធឿន បានបើកទ្វារផ្ទះខ្លួនចូលហើយក៏បិទ ខ្លួនភ្ញាក់ពីដេកក៏សួរគាត់ថានរណាគេ ក៏ឃើញឈ្មោះ[redacted] ចាន់ធឿន ដើរដល់មុខបន្ទប់ដេកខ្លួន ហើយខ្លួនក្រោកអង្គុយលើពូកក្នុងបន្ទប់ដេកដដែល តែខ្លួនឆ្ងល់ថាហេតុអីគាត់បើកទ្វារបែរជាបិទវិញ ។ ឃើញគាត់ស្លៀកកន្សែងហើយដោះអាវ ខ្លួនបានសួរគាត់ថាបងឯងមកធ្វើអី គាត់ឆ្លើយថាមានប្រេងឆារទេ ខ្លួនឆ្លើយថាមាននៅផ្ទះបាយ ស្រាប់តែពេលនោះគាត់មិនបានទៅយកប្រេងឆាទេ បែរជាដើរមករកខ្លួន ហើយក៏បានធ្វើសកម្មភាពយកដៃស្តាំបិទមាត់ខ្លួន ចំណែកដៃឆ្វេងសង្កត់ស្មារខ្លួន ពេលនោះខ្លួនរើប៉ះរាស់ដោយដៃខាងឆ្វេងខ្លួនបោចសក់គាត់ និងស្រែកថា បងពៅ កុំធ្វើអញ្ចឹងៗ ដោយស្រែកជាច្រើនដងដើម្បីឲ្យអ្នកជិតខាងលឺដែរ ។ ស្រាប់តែកូនប្រុសខ្លួនភ្ញាក់ពីដេកស្រែកយំតែម្តងហើយឈ្មោះ ពៅ គាត់បានចេញមកក្រៅផ្ទះ។ បានមួយសន្ទុះចូលមកវិញ បានលុតជង្គង់សុំទោសខ្លួន ។

នៅក្នុងរឿងនេះខ្លួនពុំទាមទារសំណងជម្ងឺចិត្តអ្វីនោះទេ ចំណែកជនជាប់ចោទសុំឲ្យតុលាការសម្រេចតាមច្បាប់ចុះ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] កក្កដា បានឆ្លើយថា ខ្លួន និងឈ្មោះ[redacted]ចាន់ធឿន បានរៀបការជាមួយគ្នានៅឆ្នាំ/

២០០៥ មានកូនប្រុសម្នាក់អាយុ៧ឆ្នាំ ហើយខ្លួនបានលែងលះគ្នាហើយ ។ ការរស់នៅជាមួយគ្នាគាត់មិនដែលវាយខ្លួនទេ ប៉ុន្តែគាត់តែងតែជេរប្រមាថរូបខ្លួនក្រោយលែងលះគ្នារួច ។ ខ្លួនបានមករស់នៅជាមួយប្អូនស្រីខ្លួនឈ្មោះ [redacted] មករា ។ ចំពោះសកម្មភាពប៉ុនប៉ងរំលោភប្អូនស្រីខ្លួននោះគឺខ្លួនមិនបានឃើញទេ ប៉ុន្តែប្អូនស្រីខ្លួនបានរៀបរាបពីសកម្មភាពអតីតប្ដីរបស់ខ្លួនបានធ្វើមកលើនាង ។

នៅក្នុងរឿងនេះខ្លួនពុំទាមទារសំណងជម្ងឺចិត្តអ្វីនោះទេ ចំណែកជនជាប់ចោទសុំឲ្យតុលាការសម្រេចតាមច្បាប់ចុះ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ៖ ឆ្លងតាមការសាកសួរដេញដោលខាងលើមកឃើញថា កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ពិតជាមានបទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលបង្កឡើងដោយឈ្មោះ [redacted] តាន់ជឿន ទៅលើជនរងគ្រោះពិតប្រាកដមែន ហើយជនជាប់ចោទក៏បានឆ្លើយសារភាព និងសុំទោសជនរងគ្រោះហើយដែរ ។ ហេតុនេះតំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឲ្យតុលាការសម្រេចតាមច្បាប់ចុះ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថា ឆ្លងតាមការសួរដេញដោលខាងលើមកឃើញថា កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ កូនក្ដីខ្លួនពិតជាបានធ្វើសកម្មភាពចូលទៅក្នុងផ្ទះជនរងគ្រោះពិតមែនដោយធ្វើសកម្មភាពយកដៃស្ដាំបិទមាត់ ដៃឆ្វេងសង្កត់ស្មារជនរងគ្រោះ ជនរងគ្រោះរើបំរាស់ដោយដៃខាងឆ្វេងបោចសក់ និងស្រែកថាបងពៅ កុំធ្វើអញ្ចឹង ដោយស្រែកជាច្រើនដងដើម្បីឲ្យអ្នកជិតខាងលឺដែរ ។ សកម្មភាពរបស់កូនក្ដីពុំខ្លួនបានធ្វើសកម្មភាពបញ្ចូលអង្គជាតិចូលទៅទ្វារមាសរបស់ជនរងគ្រោះនោះទេ បើមើលទៅលើធាតុផ្សំពុំចូលតាមមាត្រា២៣១នោះទេ ។ បើផ្អែកតាមមាត្រា៣៥០ នៃក្រមព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ស្នើសុំលើកលែងការចោទប្រកាន់ជនជាប់ចោទ ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] តាន់ជឿន ។
- ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ។
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ ។
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។
- ក្រោយពីបានពិនិត្យភស្តុតាងក្នុងសំណុំរឿង ។
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ ។

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] តាន់ជឿន (ដែលមានសាវតាជាតិដូចខាងលើ) ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ : "ប៉ុនប៉ងរំលោភសេពសន្ថវៈ" ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ ក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] តាន់ជឿន បានឆ្លើយថា ៖កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៧ និង៣០នាទីព្រឹក ខ្លួនក្រោកពីដេកស្លៀកក្រម៉ាពុំមានពាក់អាវនិងស្លៀកខោលីអូទេ បានដើរចូលទៅផ្ទះប្រពន្ធខ្លួនពេលបើទ្វារទៅឃើញឈ្មោះ [redacted] មករា កំពុងអង្គុយជាមួយកូនប្រុស អាយុប្រហែល៤ឆ្នាំ នៅមុខបន្ទប់ទ្វារដេកពេលនោះខ្លួនសុំឈ្មោះ [redacted] មករា ថាមានខ្លាញ់ទេ ពេលនោះឈ្មោះ [redacted] មករា ឆ្លើយថាខ្លាញ់មាននៅខាងក្រោយដើរទៅយកទៅ ។ ពេលនោះខ្លួនដើរទៅមិនទាន់បានយកខ្លាញ់ទេគឺចូលទៅប្រវាយប្រតប់គ្នាជាមួយឈ្មោះ [redacted] មករា ខ្លួនបានខ្ទប់មាត់ និងបំរុងធ្វើសកម្មភាពចាប់រំលោភ តែត្រូវ/



Scanned with CamScanner

ឈ្មោះ [redacted] មករា ជាក់មួយជើងចំជើងទ្រូងផ្នែកក្រោយ ហើយឈ្មោះ [redacted] មករា ស្រែកខ្លាំងៗថា អាពៅកុំធ្វើអញ្ចឹង ពេលនោ កូនរបស់ឈ្មោះ [redacted] មករា ក៏ស្រែកយំខ្លាំងៗខ្លួនបានដើរចេញមកក្រៅផ្ទះវិញ ក្រោយមកខ្លួនក៏បានលុតជង្គង់សុំទោសឈ្មោ លន់ មករា ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មករា បានឆ្លើយថា កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៦ និង៣០ នាទី អ្នកផ្ទះខ្លួនឈ្មោះ [redacted] កក្កដា បានចេញទៅលក់នំ ចំណែកកូនស្រីឈ្មោះ [redacted] សុផានីតា បានទៅរៀន កូនប្រុសឈ្មោះ [redacted] សុវណ្ណារ៉ា អាយុ៣ឆ្នាំ នៅផ្ទះជាមួយខ្លួន ។ លុះដល់ម៉ោង៧ និង៣០នាទីព្រឹក ឈ្មោះ [redacted] ចាន់ធឿន បានបើកទ្វារផ្ទះខ្លួនចូល ហើយក៏បិទ ខ្លួនភ្ញាក់ពីដេកក៏សួរគាត់ថានរណាគេ ក៏ឃើញឈ្មោះ [redacted] ចាន់ធឿន ដើរដល់មុខបន្ទប់ដេកខ្លួន ហើយខ្លួនក្រោក អង្គុយលើពូកក្នុងបន្ទប់ដេកដដែល តែខ្លួនឆ្ងល់ថាហេតុអីគាត់បើកទ្វារបែរជាបិទវិញ ។ ឃើញគាត់ស្លៀកខោខ្សែងហើយដោះអាវ ខ្លួនបានសួរគាត់ថាបងឯងមកធ្វើអី គាត់ឆ្លើយថាមានប្រេងឆារទេ ខ្លួនឆ្លើយថាមាននៅផ្ទះបាយ ស្រាប់តែពេលនោះគាត់មិនបាន ទៅយកប្រេងឆាទេ បែរជាដើរមករកខ្លួន ហើយក៏បានធ្វើសកម្មភាពយកដៃស្តាំបិទមាត់ខ្លួន ចំណែកដៃឆ្វេងសង្កត់ស្មារខ្លួន ពេល នោះខ្លួនរើបំរាស់ដោយដៃខាងឆ្វេងខ្លួនបោចសក់គាត់ និងស្រែកថា បងពៅ កុំធ្វើអញ្ចឹងៗ ដោយស្រែកជាច្រើនដងដើម្បីឲ្យអ្នក ជិតខាងលឺដែរ ។ ស្រាប់តែកូនប្រុសខ្លួនភ្ញាក់ពីដេកស្រែកយំតែម្តងហើយឈ្មោះ ពៅ គាត់បានចេញមកក្រៅផ្ទះ។ បានមួយសន្ទុះ ចូលមកវិញ បានលុតជង្គង់សុំទោសខ្លួន ។ នៅក្នុងរឿងនេះខ្លួនពុំទាមទារសំណងជម្ងឺចិត្តអ្វីនោះទេ ចំណែកជនជាប់ចោទសុំឲ្យ តុលាការសម្រេចតាមច្បាប់ចុះ ។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កក្កដា បានឆ្លើយថា ខ្លួន និងឈ្មោះ [redacted] ចាន់ធឿន បានរៀបការជាមួយគ្នានៅឆ្នាំ ២០០៥ មានកូនប្រុសម្នាក់អាយុ៧ឆ្នាំ ហើយខ្លួនបានលែងលះគ្នាហើយ ។ ការរស់នៅជាមួយគ្នាគាត់មិនដែលវាយខ្លួនទេ ប៉ុន្តែ គាត់តែងតែជេរប្រមាថរូបខ្លួនក្រោយលែងលះគ្នារួច ។ ខ្លួនបានមករស់នៅជាមួយប្អូនស្រីខ្លួនឈ្មោះ [redacted] មករា ។ ចំពោះសកម្ម ភាពប៉ុនប៉ងរំលោភប្អូនស្រីខ្លួននោះគឺខ្លួនមិនបានឃើញទេ ប៉ុន្តែប្អូនស្រីខ្លួនបានរៀបរាបពីសកម្មភាពអតីតប្តីរបស់ខ្លួនបានធ្វើមក លើនាង ។ នៅក្នុងរឿងនេះខ្លួនពុំទាមទារសំណងជម្ងឺចិត្តអ្វីនោះទេ ចំណែកជនជាប់ចោទសុំឲ្យតុលាការសម្រេចតាមច្បាប់ចុះ។

៥-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ ស៊ីសង្វាក់នឹងចម្លើយដាក់បន្ទុករបស់ជនរងគ្រោះឈ្មោះ [redacted] មករា និង សាក្សីឈ្មោះ [redacted] កក្កដា និងរបាយការណ៍សំយោគលេខ ៖១៣១/២២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រនៃ ស្នងការនគរបាលខេត្តសៀមរាប ហាក់បង្ហាញឲ្យឃើញថា ជនជាប់ចោទពិតជាបានប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើជនរងគ្រោះ ពិតមែន ដោយជនជាប់ចោទស្លៀកខោខ្សែងហើយដោះអាវ និងបានធ្វើសកម្មភាពយកដៃស្តាំបិទមាត់ជនរងគ្រោះចំណែកដៃឆ្វេង សង្កត់ស្មារជនរងគ្រោះ ពេលនោះជនរងគ្រោះរើបំរាស់ដោយដៃខាងឆ្វេងជនរងគ្រោះបោចសក់ជនជាប់ចោទ និងស្រែកថា បង ពៅ កុំធ្វើអញ្ចឹងៗ ដោយស្រែកជាច្រើនដងដើម្បីឲ្យអ្នកជិតខាងលឺដែរ។ ពេលនោះស្រាប់តែកូនប្រុសជនរងគ្រោះបានភ្ញាក់ហើយ ស្រែកបានធ្វើឲ្យជនជាប់ចោទក៏យរត់ចេញទៅបាត់ទៅ។ ដែលអំពើនេះគឺពិតជាអំពើប៉ុនប៉ងរំលោភសេពសន្ថវៈ ពិតមែន ។

៦-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន តាមសាវតាជាតិដែលទទួលបានបញ្ជាក់ថាមានអាយុ៤១ឆ្នាំគឺជានីតិជន។ ដូច្នេះ ផ្អែកតាមមាត្រា៣៨នៃក្រមព្រហ្មទណ្ឌបានចែងថា មាននីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងជាជនដែលមានការយល់ ដឹងអាចថ្លឹងថ្លែងនូវអំពើរបស់ខ្លួនបាន ។

៧-ជនជាប់ចោទបានប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើជនរងគ្រោះបើទោះបីជនរងគ្រោះជាមានប្តីហើយក៏ដោយ គំនិត



Scanned with CamScanner

ទុច្ចរិតរបស់ជនជាប់ចោទគឺបានបំផ្លាញកិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ហើយមិនមែនជាលើកទី១ទេដែលជនជាប់ចោទបានប្រព្រឹត្តអំពើអសីលធម៌ទៅលើជនរងគ្រោះ ជនជាប់ចោទក៏ធ្លាប់មានគំនិតមិនល្អទៅលើបងស្រីជនរងគ្រោះពីមុនមកដែរ។ ចំណុចនេះបានបង្ហាញឲ្យឃើញពីចេតនា និងឆន្ទៈយ៉ាងពិតប្រាកដក្នុងការប្រព្រឹត្តបទល្មើសដែលជាធាតុផ្សំនៃបទល្មើស ។

៨-យោងតាមការយល់ឃើញខាងលើឃើញថា ទង្វើរបស់ជនជាប់ចោទ គឺជាអំពើល្មើសនឹងច្បាប់ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។ ហេតុដូច្នេះប្រកាសទោសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

៩-ជនរងគ្រោះឈ្មោះ [redacted] មកក មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរនិងដំណាក់កាលចៅក្រមជំនុំជម្រះនោះទេ ។ ដូច្នេះតុលាការនឹងមិនពិចារណានិងសម្រេចអំពីសំណងរដ្ឋប្បវេណីឡើយ ។

១០-ដោយសារជនជាប់ចោទមិនធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីបទល្មើសណាមួយពីមុនមក លើសពីនេះជនរងគ្រោះក៏មិនបានទាមទារសំណងនោះដែរ និងដោយពិចារណាឃើញថាបទល្មើសមិនទាន់បានសម្រេច ព្យសនកម្មក៏មិនទាន់កើតមានឡើង ។ ដូច្នេះតុលាការនឹងសម្រេចផ្តន្ទាទោសជនជាប់ចោទក្នុងកម្រិតអប្បបរិមានៃទោស ។

១១-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ : តម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឲ្យតុលាការសម្រេចតាមច្បាប់ចុះ ។ ផ្អែកតាមការយល់ឃើញក្នុងចំណុចទី១.២.៣.៤.៥.៦.៧និង៨ ខាងលើគប្បីតុលាការសម្រេចតាមការប្តឹងសុំរបស់តំណាងអយ្យការ ។

១២-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា ឆ្លងតាមការសួរដេញដោលខាងលើមកឃើញថា កូនក្តីខ្លួនមិនបានប៉ុនប៉ងរំលោភសេពសន្ថវៈ ទៅលើជនរងគ្រោះនោះទេ ។ ចំណុចនេះអាចជឿបានព្រោះនៅគ្រប់ដំណាក់កាលនៃនីតិវិធីជនរងគ្រោះមិនបានឆ្លើយប្រកែកឡើយ ហើយជនរងគ្រោះក៏ជាអតីតប្អូនថ្លៃជនជាប់ចោទដែរ ។ ហេតុនេះខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសំនូមពរឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ដោយខ្វះធាតុផ្សំនៃបទល្មើស គឺខ្វះធាតុអត្តនោម័តផ្អែកតាមមាត្រា៤ នៃក្រមព្រហ្មទណ្ឌដោយក្តីអនុគ្រោះ ។ ផ្អែកតាមការយល់ឃើញក្នុងចំណុចទី១.២.៣.៤.៥.៦.៧.៨ និង ១១ ខាងលើ គប្បីតុលាការមិនសម្រេចតាមការប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឡើយ ។

១៣-មានពិរុទ្ធភាព និងជាតុផ្សំដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ពីបទ " ប៉ុនប៉ងរំលោភសេពសន្ថវៈ " ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះសម្រេច</u>

១- **<u>ផ្តន្ទាទោសលើជនជាប់ចោទ៖</u>**

ក-ឈ្មោះ [redacted] **ចាន់ធឿន** ហៅ ពៅ ភេទប្រុស (កើតឆ្នាំ១៩៨៥) អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ ។

ពីបទ " **ប៉ុនប៉ងរំលោភសេពសន្ថវៈ** " ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩



Scanned with CamScanner

នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសសាលក្រមនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ។

ទុកសិទ្ធិឲ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា**
[redacted]

**ក្រុមប្រឹក្សាជំនុំជម្រះ**
**ហត្ថលេខា និងត្រា**
[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
**ហត្ថលេខា និងត្រា**
[redacted]

---

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
សៀមរាប ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]